ក

## មាតិកា

# I-ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ


១០-៤-២០០១ ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧០ ស្ដីពីការបង្កើតនិង គ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាប ១០០៧

០៩-៤-២០០១ ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧២ បំពាក់មេដាយព្រះរាជាណាចក្រកម្ពុជា ថ្នាក់សេនា ជាកិច្ចបច្ឆាមរណៈ ជូនចំពោះ សព ឯកឧត្តម **ឈា សុខ** ១០១៤

១០-៤-២០០១ ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧៣ តែងតាំង ឯកឧត្តម **ហាវ ម៉ុនសែ ឡុង ផុល** ជាទីប្រឹក្សាផ្ទាល់ សម្ដេចនាយករដ្ឋមន្ត្រី ១០១៥

១២-៤-២០០១ ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧៤ តែងតាំង ឯកឧត្តម **ឌុច សុវណ្ណារី** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ចការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ១០១៦

១៩-៤-២០០១ ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧៦ តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ឯក ជូនឧត្តមសេនីយទោ **ខ្វាន់ ស៊ាម** ឧត្តមសេនីយ៍ទោ **ឈុំ សុជាតិ** ១០១៧

២០-៤-២០០១ ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧៧ ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហ្វាង មូជួន** (HUANG MUCHUAN) ១០១៨

២១-៤-២០០១ ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧៩ ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោកស្រី **អ៊ូ អ៊ីហ៊័រ** (WU YUHUA) ១០១៩

២១-៤-២០០១ ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៨០ ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **បឺណ័រ ឌុយសាតូអាមាំងហ្សុង** (BENOIT DUCHATEAU-ARMINJON) ហៅ (BENITO) ១០២០

២១-៤-២០០១ ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៨១ តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយទោ ជាកិច្ចបច្ឆាមរណៈ ចំពោះសព ឧត្តមសេនីយត្រី **ជា នាយ៉ា** ឧត្តមសេនីយត្រី **ជាំ ពេជ្ជលី** ១០២១

២១-៤-២០០១ ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៨២ តម្លើងឋានន្តរសក្តិឧត្តមសេនីយ៍ត្រី ជូន វរសេនីយ៍ឯក **ខេង គឹមហាន** ១០២២

## II- រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ

១៨-៤-២០០១ អនុក្រឹត្យលេខ ១៥៤ អនក្រ- តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១០២៣

២៣-៤-២០០១ អនុក្រឹត្យលេខ ១៥៥ អនក្រ- តត ស្តីពីការជូនមេដាយ ស្ថាបនាជាតិ ១០២៤

២៣-៤-២០០១ អនុក្រឹត្យលេខ ១៥៦ អនក្រ- តត ស្តីពីការជូនមេដាយការងារ ១០២៦

២៣-៤-២០០១ អនុក្រឹត្យលេខ ១៥៧ អនក្រ- តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០២៨

២៣-៤-២០០១ អនុក្រឹត្យលេខ ១៥៨ អនក្រ- តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៣០

៣-៤-២០០១ អនុក្រឹត្យលេខ ១៥៩ អនក្រ- តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៣១

៤-២០០១ អនុក្រឹត្យលេខ ១៦០ អនក្រ- តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៣៣

៤-២០០១ អនុក្រឹត្យលេខ ១៦១ អនក្រ- តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៣៥

៣-៤-២០០១ អនុក្រឹត្យលេខ ១៦២ អនក្រ- តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៣៦

២៣-៤-២០០១ អនុក្រឹត្យលេខ ១៦៣ អនក្រ- តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៣៧

### ២. សេចក្តីសំរេច

១៨-៤-២០០១ សេចក្តីសំរេចលេខ ២០ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដោះស្រាយ ដីដែលមានទីតាំង នៅខាងក្រោយជាប់ អូតែល សុខា ក្រុងព្រះសីហនុ ១០៣៨

## III- ការិយាល័យក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

#### ប្រកាស

១២-៤-២០០១ ប្រកាសលេខ ២៧៧ ឧរថកឧ.ប្រក អនុញ្ញាតអោយលោក **តាំង សេងសៀវ** សញ្ជាតិកម្ពុជា បង្កើតសហគ្រាសផលិតកាបូប វ៉ាលីស ១០៤០

១២-៤-២០០១ ប្រកាសលេខ ២៧៨ ឧរថកឧ.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ( ខេមបូឌៀរ ) ហ្សុងហ្សិន អ៊ិនជីនារីង អេនមីស៊ីណឺរី ខូអិលធីឌី តំណាងដោយលោក CHENG CHUNG KONG បង្កើតរោងចក្រ ផ្គុំតម្លើងម៉ូតូ ១០៤២

## ២ ~ ទីស្តីការរដ្ឋមន្ត្រីក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

### ប្រកាស

១០-៤-២០០១ ប្រកាសលេខ ០០៧/០១ ទរព.អ. ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១០៤៣

## ៣~ ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

### សេចក្តីសំរេច

១៩-៤-២០០១ សេចក្តីសំរេចលេខ ៩១ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ត ឈ្មោះ **ក្រុមជំនុំព្រះជាម្ចាស់ខេត្ត សៀមរាប** ស្ថិតនៅភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ១០៤៥

២០-៤-២០០១ សេចក្តីសំរេចលេខ ៩២ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ត ឈ្មោះ **ព័ន្ធកិច្ចពេនទីកូសបរិសុទ្ធបេសកកម្មពិភពលោក** ស្ថិតនៅផ្ទះលេខ ៤៥ សេ ក្រុមទី ១០ សង្កាត់ទួលទំពូង២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ១០៤៦

២០-៤-២០០១ សេចក្តីសំរេចលេខ ៩៣ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំនៃព្រះពុទ្ធសាសនា មហាយានមីឡឺ(ចិន) ឈ្មោះ **ឆៀនឈឿមីឡឺ** ស្ថិតនៅផ្ទះលេខ ៧៧.AEO ផ្លូវលេខ៣ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ១០៤៨

២០-៤-២០០១ សេចក្តីសំរេចលេខ ៩៤ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ត ឈ្មោះ **ភាតូលីកភូមិថ្មពេជ្រ ទី២** ស្ថិតនៅផ្ទះលេខ ៣៦ ក្រុមទី ១១ ភូមិថ្មពេជ្រ ទី២ ឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ ចាម ១០៤៩

២០-៤-២០០១ សេចក្តីសំរេចលេខ ៩៥ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះពុទ្ធសាសនា មហាយានមីឡឺ (ចិន) មានឈ្មោះថា " **ធានយាន** " ស្ថិតនៅផ្ទះលេខ ២៤ ផ្លូវលេខ៧ ក្រុមទី ១ ភូមិមេមត់កណ្តាល ស្រុក មេមត់ ខេត្តកំពង់ ចាម ១០៥១

# I-ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧០

### ស្តីពីការបង្កើត

### និងគ្រប់គ្រងតំបន់ជីវមណ្ឌលបឹងទន្លេសាប

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

### ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានទ្រង់យល់ក្រឹត្យច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនាឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល

.-បានទ្រង់យល់លក្ខន្តិកៈនៃប្រព័ន្ធបណ្តាញជីវមណ្ឌលពិភពលោក ដែលបានអនុម័តនៅក្នុងមហាសន្និបាតទូទៅរបស់ អង្គ ការ យូណេស្កូ នៅថ្ងៃទី ២០ ដល់ ២៥ ខែមិនា ឆ្នាំ ១៩៩៥

-បានទ្រង់យលសេចក្តីសំរេចទទួលស្គាល់ជាផ្លូវការរបស់ក្រុមប្រឹក្សាសំរបសំរួលអន្តរជាតិ សំរាប់កម្មវិធីមនុស្ស និងជីវមណ្ឌលរបស់អង្គការយូណេស្កូ ក្នុងការបញ្ចូលបឹងទន្លេសាប ទៅក្នុងប្រព័ន្ធថបនីយជីវមណ្ឌលពិភពលោក នៅក្នុងសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសំរបសំរួល អន្តរជាតិ នៅថ្ងៃទី ២៧.-២៩ខែតុលា ឆ្នាំ ១៩៩៧

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នៅថ្ងៃ ទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០១

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតថបនីយជីវមណ្ឌលបឹងទន្លេសាប ដោយផ្អែកលើសារៈសំខាន់នៃប្រព័ន្ធអេកូឡូស៊ី បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌បឹងទន្លេសាប ស្របតាមលក្ខន្តិកៈស្តីពីប្រព័ន្ធ ថបនីយជីវមណ្ឌលពិភពលោក ។ការបង្កើតថបនីយជីវមណ្ឌលបឹងទន្លេសាបនេះ មានគោលបំណងសំខាន់ ៣ គឺ :

១-អភិរក្សជីវចំរុះ ទេសភាព សណ្ឋានដី និងប្រព័ន្ធអេកូឡូស៊ី រួមទាំងធនធានសេនេទិច ប្រភេទរុក្ខជាតិ មច្ឆាជាតិ និងសត្វ ព្រមទាំងស្តារឡើងវិញនូវបរិស្ថាន និងទីជម្រកនៃជីវចំរុះ ។

២-ទ្រទ្រង់ឱ្យមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពលើប្រព័ន្ធអេកូឡូស៊ីបរិស្ថានសេដ្ឋកិច្ច សង្គម និង វប្បធម៌

៣- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការអនុវត្តគម្រោងបង្ហាញ ការអប់រំបណ្តុះបណ្តាលការសិក្សា-ស្រាវជ្រាវ និងការអង្កេតតាមដានការប្រែប្រួលបរិស្ថាន ដែលទាក់ទង នឹងការអភិវឌ្ឍន៍ដោយនិរន្តរភាព ការអភិរក្សនៅក្នុងកំរិតមូលដ្ឋាន កម្រិតជាតិ និងអន្តរជាតិ ។

## ជំពូកទី ២

## ទីតាំងភូមិសាស្ត្រនៃថបនីយជីវមណ្ឌលបឹងទន្លេសាប

**មាត្រា២.-**ដើម្បីអនុវត្តនូវគោលបំណងសំខាន់ទាំងបី ដូចបានកំណត់ក្នុងមាត្រា ១ ថបនីយជីវមណ្ឌល បឹងទន្លេសាប ត្រូវបែងចែកជាបីតំបន់គឺ តំបន់ស្នូល តំបន់ទ្រនាប់ និងអន្តរតំបន់ ។

ថបនីយជីវមណ្ឌលបឹងទន្លេសាបមានព្រំប្រទល់ ខាងលិចទល់នឹងផ្លូវជាតិលេខ៥ ខាងកើតទល់និងផ្លូវជាតិលេខ ៦ ខាងជើងកំណត់ត្រឹមចំណុចប្រសព្វ នៃផ្លូវជាតិលេខ៥ និងលេខ៦ ( 13° 36’52’’N,103° 06’32’’E ) និងខាងត្បូងត្រឹមឃុំសែប ( 12° 05’ 06 N 104° 43 39 E) ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ផែនទីព្រំប្រទល់ និងនិយាមការនៃថបនីយមណ្ឌលបឹងទន្លេសាប មានក្នុងឧបសម្ពន្ធ័ទី១ និងឧបសម្ពន្ធ័ទី២ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.~**

តំបន់ស្នូលមានបីគឺ :

១-តំបន់ស្នូលព្រែកទាល់ មានទីតាំងស្ថិតនៅក្នុងឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ហើយមានផ្ទៃក្រឡា ២១.៣៤២ ហិកតា ។

២-តំបន់ស្នូលបឹងទន្លេឆ្មារ មានទីតាំងនៅស្ថិតក្នុង ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ហើយមានផ្ទៃក្រឡា១៤.៥៦០ ហិកតា ។

៣-តំបន់ស្នូលស្ទឹងសែន មានទីតាំងស្ថិតនៅក្នុង ឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ហើយមានផ្ទៃក្រឡា ៦.៣៥៥ ហិកតា ។

តំបន់ស្នូលមានសារៈប្រយោជន៍ និងតំលៃស្មើនឹងឧទ្យានជាតិ ឬដែនជំរកសត្វព្រៃ ដែលកំណត់សម្រាប់ការពារ និងអភិរក្សយូរអង្វែងនូវធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី ដើម្បីរក្សាអោយបានគង់វង្សនូវព្រៃលិចទឹក មច្ឆាជាតិ សត្វព្រៃគ្រប់ប្រភេទ ប្រពន្ធ័ជលសាស្ត្រ និងសោភណភាពនៃធម្មជាតិ ។ តំបន់ស្នូលអនុញ្ញាតឱ្យមានសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រការអង្កេតតាមដាន និងអេកូទេសចរណ៍។ តំបន់នេះមិនអនុញ្ញាតឱ្យមានសកម្មភាពណាមួយ ដែលធ្វើឱ្យរេចរិល ឬបំផ្លាញជីវចម្រុះឡើយ ។

ឡូត៍នេសាទ ដែលមានតំបន់ស្នូលស្ថិតនៅខាងក្នុងនឹងបន្តធ្វើអាជីវកម្មស្របតាមច្បាប់ជលផលហើយម្ចាស់ឡូត៍នេសាទត្រូវយកចិត្តទុកដាក់ចូលរួមចំណែកអនុវត្តនូវទិសដៅអភិរក្សយូរអង្វែងដូចបានកំណត់ខាងលើ ។ ឡូត៍នេសាទទាំងនេះត្រូវទទួលការត្រួតពិនិត្យ និងវាយតម្លៃ ក្នុងរយៈពេល ៤ឆ្នាំម្តង ហើយត្រូវធ្វើកំណែទម្រង់សមស្របដើម្បីឱ្យស៊ីសង្វាក់ទៅនឹងទិសដៅការពារ និងអភិរក្សយូរអង្វែងនៃតំបន់ស្នូល ។

ការនេសាទរបស់ប្រជាពលរដ្ឋជាលក្ខណៈគ្រួសារ និងលក្ខណៈសិប្បកម្មដែលស្ថិតនៅក្នុងតំបន់ស្នូលខាងក្នុងត្រូវបន្តអាជីវកម្ម ស្របតាមច្បាប់ជលផលដោយមានការរៀបចំជាសហគមន៍នេសាទ ដើម្បីចូលរួមការពារស្របតាមស្មារតីព្រះរាជក្រឹត្យ ។

**មាត្រា៤.~**

តំបន់ទ្រនាប់មានផ្ទៃក្រឡា៥៤១.៤៨២ហិកតា ដែលមានព្រំប្រទល់ត្រួតស៊ីគ្នានឹងព្រំប្រទល់ខាងក្រៅនៃតំបន់ប្រើប្រាស់ច្រើនយ៉ាង នៃបឹងទន្លេសាប ។ តំបន់ទ្រនាប់ជាតំបន់ព័ទ្ធជុំវិញតំបន់ស្នូល ដែល គ្របដណ្តប់ដោយព្រៃលិចទឹកគ្រប់ប្រភេទ។

សកម្មភាពរបស់មនុស្សត្រូវបានគ្រប់គ្រងឱ្យបានសមស្រប ដោយស៊ីសង្វាក់នឹងផែនការការពារ និងអភិរក្សនៃតំបន់ស្នូល ។ សកម្មភាពនេសាទនិងអភិវឌ្ឍន៍ផ្សេងៗនឹងបន្តដំណើរ ការគ្រប់គ្រងដោយច្បាប់ដែលមានស្រាប់ដោយឈរលើស្មារតីសហការ និងសម្របសម្រួលរវាងក្រសួងពាក់ព័ន្ធ ។ តំបន់នេះ ក៏ជាកន្លែងសំរាប់ការពិសោធន៍ ស្រាវជ្រាវនូវវិធីសាស្ត្រគ្រប់គ្រងព្រៃលិចទឹក នេសាទកសិកម្ម ការតាំងលំនៅដ្ឋាន ការប្រើប្រាស់ដីធ្លីធនធានទឹក នាវាចរណ៍ ទេសចរណ៍ដែលអាច-ធានានិរន្តរភាព បង្កើនផលិតកម្មដោយរក្សាឱ្យបាននូវគុណភាពបរិស្ថាន និងមច្ឆាជាតិ ។

**មាត្រា៥.-**

អន្តរតំបន់ជាតំបន់នៅជុំវិញតំបន់ទ្រនាប់ មានផ្ទៃដី ៨៩៩.៦០០ហិកតា ស្ថិតនៅចន្លោះព្រំប្រទល់តំបន់ទ្រនាប់និងផ្លូវជាតិលេខ៦ និងលេខ ៥ ។

អន្តរតំបន់ជាតំបន់សេដ្ឋកិច្ចចម្រុះ ត្រូវរៀបចំឱ្យបានសមស្របសំដៅធានានិរន្តរភាពកសិកម្ម ការតាំងលំនៅដ្ឋាន និងការប្រើប្រាស់ដីផ្សេងៗដោយមិនធ្វើឱ្យមានឥទ្ធិពលអាក្រក់ទៅលើព្រៃលិចទឹក គុណភាពទឹក និងដី នៅក្នុងតំបន់ជុំវិញបឹងទន្លេសាប ។

## ជំពូកទី III

## រដ្ឋបាល និងការគ្រប់គ្រង

**មាត្រា៦.-**

ដើម្បីជួយសម្របសម្រួល ពង្រឹងការងារទំនាក់ទំនង និងសហប្រតិបត្តិការរវាងក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ក្នុងកិច្ចការពារ និងគ្រប់គ្រងជីវមណ្ឌលបឹងទន្លេសាបប្រកបដោយនិរន្តរភាពចាំបាច់ត្រូវបង្កើតលេខាធិការដ្ឋានជីវមណ្ឌលបឹងទន្លេសាបដែលស្ថិតនៅក្រោមគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។ ការបង្កើតការរៀបចំនិងការប្រព្រឹត្តិទៅនៃលេខាធិការដ្ឋានជីវមណ្ឌលបឹងទន្លេសាបត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៧.-**

ក្រសួងបរិស្ថានទទួលខុសត្រូវក្នុងការគ្រប់គ្រង ការធ្វើផែនការការពារ និងអភិរក្សតំបន់ស្នូលនៃជីវមណ្ឌលបឹងទន្លេសាប តាមរយៈការសម្របសម្រួលរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ សហគមន៍មូលដ្ឋាននិងអាជ្ញាធរដែនដី ផ្អែកលើ មាត្រា៣នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី ៤
## ការកែប្រែព្រំប្រទល់

**មាត្រា៨.-**

ការគ្រប់គ្រងតំបន់ទ្រនាប់ និងអន្តរតំបន់ ត្រូវអនុវត្តតាមផែនការរបស់ក្រសួងជំនាញពាក់ព័ន្ធ តាមរយៈការសំរបសំរួលរបស់គណៈកម្មាធិការជាតិទន្លេ មេគង្គកម្ពុជា ស្របតាមមាត្រា៤និងមាត្រា ៥ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៩.-**

ព្រំប្រទល់ និងសកម្មភាពនៃតំបន់នីមួយៗនៃ ជីវមណ្ឌលបឹងទន្លេសាបនេះ អាចនឹងកែប្រែបាន ដោយផ្អែកលើពត៌មានវិទ្យាសាស្ត្រជាមូលដ្ឋាន និងស្ថានភាពជាក់ស្តែងដែលទាក់ទងទៅនឹងការ អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ការអភិរក្សជីវចម្រុះ និងរក្សាការពារនិរន្តរភាពបរិស្ថាន ដូចចែងក្នុងមាត្រា ៣ មាត្រា៤ និងមាត្រា៥នៃព្រះរាជក្រឹត្យនេះ ។

ការកែប្រែព្រំប្រទល់និងសកម្មភាពនៃតំបន់នីមួយៗនៃ ជីវមណ្ឌលបឹងទន្លេសាប ត្រូវកំណត់ ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថានដោយមានការយល់ព្រមពីក្រសួងស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-** បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

**មាត្រា ១១.-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះប្រកបដោយប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី១០ ខែ មេសា ឆ្នាំ ២០០១

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងបរិស្ថាន

ហត្ថលេខា

**ម៉ុក ម៉ារ៉េត**

## ឧបសម្ព័ន្ធ ទី ១ (ផែនទីបឹងទន្លេសាប)

## ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យ ស្ដីពីការបង្កើត និងការគ្រប់គ្រងជីវមណ្ឌលបឹងទន្លេសាប

លេខ....... ចុះថ្ងៃទី .........ខែ.......ឆ្នាំ ២០០១

| N⁰ | ឈ្មោះទីតាំងនិងសញ្ញាសំគាល់ | | ដឺគ្រេ( Drgrees) | | ម៉ែត្រ( UTM ) | |
|---|---|---|---|---|---|---|
| | | | រយៈទទឹង(N) | រយៈបណ្ដោយ(E) | រយៈទទឹង(N) | រយៈបណ្ដោយ(E) |
| | **តំបន់ស្នូល** | | | | | |
| | **ក. តំបន់ស្នូលព្រែកទាល់** | | | | | |
| ១ | ស្ទឹងចាស់ | A1 | 13°13′05" | 103°36′39" | 1461580 | 349500 |
| ២ | កំពង់ប្រហុក | A2 | 13°13′57" | 103°38′55" | 1463160 | 353600 |
| ៣ | កោះក្អែក | A3 | 13°12′17" | 103°41′49" | 1460070 | 358805 |
| ៤ | ពាក់ ទ្រែល | A4 | 13°06′51" | 103°42′36" | 1450035 | 360154 |
| 5 | បឹងវែង | A5 | 13°03′52" | 103°37′02" | 1444600 | 350080 |
| 6 | បឹងវែង | A6 | 13°05′57" | 103°33′42" | 1448450 | 344096 |
| | **ខ. តំបន់ស្នូលបឹងទន្លេឆ្មារ** | | | | | |
| 1 | បាឡត់ | B 1 | 12°44′30" | 104°20′57" | 1408568 | 429350 |
| 2 | ពាមបាង | B2 | 12°43′50" | 104°16′51" | 1407360 | 421924 |
| 3 | B3 | | 12°36′46" | 104°14′52" | 1412410 | 418380 |
| 4 | B4 | | 12°49′42" | 104°14′45" | 1418210 | 418154 |
| 5 | B5 | | 12°51′59" | 104°17′10" | 1422400 | 422564 |
| | B6 | | 12°51′12" | 104°21′22" | 1420890 | 430142 |
| | **ខ. តំបន់ស្នូលស្ទឹងសែន** | | | | | |
| 1 | C1 | | 12°33′30" | 104°30′13" | 1388220 | 446090 |

| | | | | | | |
|---|---|---|---|---|---|---|
| 2 | C2 | | 12°34′28¨ | 104°28′47¨ | 1390060 | 443504 |
| 3 | C3 | | 12°37′00¨ | 104°29′42¨ | 1394730 | .445173 |
| 4 | C4 | | 12°40′02¨ | 104°31′24¨ | .1400320 | .448259 |
| 5 | C5 | | 12°38′33¨ | 104°33′31¨ | .1397570 | .452097 |
| 6 | C6 | | 12°35′57¨ | 104°33′08¨ | .1392890 | .551346 |

## II..តំបន់ត្រនាប់

| | | | | | | |
|---|---|---|---|---|---|---|
| 1 | តាមុន | D1 | 13°18′18¨ | 103°14′11¨ | 1471500 | 309000 |
| 2 | ឡូត៍នៃសាទលេខ | D2 | 13°18′19¨ | 103°14′12¨ | 1460330 | .325730 |
| 3 | សំបួរ | D3 | 13°27′41¨ | 103°28′25¨ | .1488700 | .334700 |
| 4 | កំពង់ភ្លុក | D4 | 13°13′35¨ | 103°58′39¨ | .1462300 | .389100 |
| 5 | ម្យាក្រង | D5 | 12°52′16¨ | 104°24′19¨ | .1424700 | .435400 |
| 6 | ពោធិ | D6 | 12°21′39¨ | 104°40′09¨ | .1360400 | .464000 |
| 7 | ក្រគរ | D7 | 12°32′01¨ | 104°24′43¨ | .1385600 | .417100 |
| 8 | មេទឹក | D8 | 12°50′42¨ | 103°51′53¨ | .1421100 | .3733400 |

## III..អន្តរតំបន់

| | | | | | | |
|---|---|---|---|---|---|---|
| 1 | សែប | E1 | 12°05′06¨ | 104°43′39¨ | 1332200 | 470300 |
| 2 | កោះថ្កូវ | E2 | 12°04′21¨ | 104°49′34¨ | .1334500 | .481000 |
| 3 | ជលគីរី | E3 | 12°09′27¨ | 104°52′27¨ | .1343600 | .486200 |
| 4 | សំរោងសែន | E4 | 12°21′27¨ | 104°52′17¨ | 1365700 | .486300 |
| 5 | ស្ទឹងសែន | E5 | 12°43′05¨ | 104°43′18¨ | .1405900 | .469800 |
| 6 | ស្មោង | E6 | 12°56′36¨ | 104°34′18¨ | .1438000 | .453500 |
| 7 | សៀមរាប | E7 | 13°20′21¨ | 103°59′49¨ | .1474800 | .391300 |
| 8 | ស៊ីសុផុន | E8 | 13°36′52¨ | 103°06′32¨ | .1505900 | .284800 |
| 9 | បាត់តំបង | E9 | 13°05′36¨ | 103°12′06¨ | .1448000 | .305000 |
| 10 | ពោធិសាត់ | E10 | 12°32′00¨ | 103°55′23¨ | .1385400 | .383000 |
| 11 | កំពង់ឆ្នាំង | E11 | 12°15′08¨ | 104°40′20¨ | .1354300 | .464200 |
| 12 | អណ្តូងស្វាយ | E12 | 12°21′17¨ | 104°52′47¨ | .1340600 | .466600 |
| 13 | ព្រៃស្វាយ | E13 | 12°41′52¨ | 103°36′00¨ | .1406500 | .338800 |

## ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

---

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៩ ខែ តុលាឆ្នាំ១៩៩៥ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០១

**ត្រាស់បង្គាប់**

**មាត្រា១.**-ត្រូវបានបំពាក់ **មេដាយព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជាកិច្ចបច្ចាមរណៈជូនចំពោះ សព ឯកឧត្តម **ឈា សុខ** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

**មាត្រា២.**-នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.**-ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០១

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

---

## ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧៣

# ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧៣

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

---

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា១.-** ត្រូវបានតែងតាំងឯកឧត្តមចំនួន ០២រូប ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើអនុរដ្ឋលេខាធិការ ដូចមានរាយនាមខាងក្រោម ៖

១-ឯកឧត្តម **ហាវ ម៉ុនសែ** ២-ឯកឧត្តម **ឡូង ផុល**

**មាត្រា២.-** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ .-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៤.-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០១

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

# ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

---

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើ សុំរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា១.-** តែងតាំងឯកឧត្តម **ឌុច សុវណ្ណារី** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវ នីតិសម្បទា ។

**មាត្រា២ .-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

**ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧៦**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

---

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាស ឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៧ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាននៃកងយោធពល ខេមរភូមិន្ទ

-បានទ្រង់យល់សំណើនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០១

**ត្រាស់បង្គាប់**

**មាត្រា១.**-ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ឯកជូននាយទាហានជាន់ខ្ពស់នៃ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ ចំនួន០២រូប ដូចមានរាយនាមខាងក្រោម :

១-ឧត្តមសេនីយ៍ទោ **ខ្វាន់ សារិម** អត្តលេខ ០០០១០៨ បច្ចុប្បន្ន មេបញ្ជាការកងវិស្វកម្មនៃ តាំងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ។

២-ឧត្តមសេនីយ៍ទោ **ឈុំ សុជាតិ** អត្តលេខ ០០០០៣០ បច្ចុប្បន្ន នាយកទីចាត់ការការងារព្រំដែននៃ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ។

**មាត្រា២.-** បទប្បញ្ញត្តិទាំងឡាយណាមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣.-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤.-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០១

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

---

**ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧៧**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

---

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

.-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាស ឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ចុះថ្ងៃទី០៩ខែតុលា ឆ្នាំ ១៩៩៦ស្តីពីការប្រកាស ឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា១.**-ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ហួង មូជុន** (HUANG MU CHAN ) សញ្ជាតិដើមចិន កើតនៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ១៩៣៧ នៅកោះតៃវ៉ាន់ប្រទេសចិន ។

**មាត្រា២ .**- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.**-ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

---

## ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៧៩

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

---

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិ ទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/១០៩៦/៣០ចុះថ្ងៃទី០៩ខែតុលា ឆ្នាំ ១៩៩៦ ប្រកាស ឱ្យប្រើច្បាប់ស្ដីពីសញ្ជាតិ

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា១.-** ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **អ៊ូ អ៊ីហ័រ** (WU YU HUA ) សញ្ជាតិដើមចិន កើតនៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៦០នៅក្រុងតៃប៉ិ ប្រទេសចិន ។

**មាត្រា២.-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០១

**ព្រះហស្ថលេខា**

**នរោត្ដម សីហនុ**

---

## ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៨០

## យើង

## ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

---

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

.-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ចុះថ្ងៃទី០៩ខែតុលា ឆ្នាំ ១៩៩៦ ប្រកាស ឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា១.-** ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **ប៊ីណរ៉ ឌុយសាតូអាមាំងហ្សុង** (BENOIT DUCHATEAU>-ARMINJON ) ហៅ ប៊ីនីតូ (BENITO) សញ្ជាតិដើមបារាំង កើតនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៦៦នៅបូរមបេរី សារ៉ាវ សាធារណរដ្ឋបារាំង។

**មាត្រា២.-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

## ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៨១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

---

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

.-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ចុះថ្ងៃទី២៤ខែមករាឆ្នាំ ១៩៩៦ ប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា១.-** តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈ ចំពោះសព ឧត្តមសេនីយ៍ត្រី **ខាំ ឆាយ៉ា** អត្តលេខ ០០០៤៨៣ នាយករង នាយកដ្ឋានស្រាវជ្រាវចារកិច្ច ។

**មាត្រា២.-** តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈ ចំពោះសព វរសេនីយ៍ឯក **ជាំ ពេជ្រលី** អត្តលេខ ០០០៨៨១ នាយសេនាធិការរង យោធភូមិភាគទី១ ។

**មាត្រា៣ .-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤.-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

---

## ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨២

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

---

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

.-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា១.-** ត្រូវតម្លើងឋានន្តរសក្តិ ថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **ខង្ស គឹមហាន** អត្តលេខ ០០០៣៨០ នាយសេនាធិការរង យោធភូមិភាគពិសេស បច្ចុប្បន្នទីប្រឹក្សាក្រសួងការពារជាតិ ។

**មាត្រា២.-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ១៥៤ អនក្រ.-តត

### ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

---

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាស ប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

**សំរេច**

**មាត្រា១.-** ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនអ្នកឧកញ៉ាធិបតី **ហេង គីមគុណ** ដែលមានស្នាដៃ ក្នុងវិស័យព្រះពុទ្ធសាសនា និងទំនៀមទំលាប់ប្រពៃណីខ្មែរ ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០១

ហត្ថលេខានិងត្រា

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**អនុក្រឹត្យ លេខ ១៥៥ អនក្រ.-តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

~~~

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
~~~

**សំរេច**

**មាត្រា១.-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ជនជាតិជប៉ុន ចំនួន ០៧ រូបជាស្ថាបនិកសំខាន់ៗ របស់អង្គ ការមូលនិធិខ្មែរជំនួយការសិក្សា" CEAF ដែលបាន ចំណាយថវិកាចំនួន ១១៤.៩៣២ ដុល្លារអាមេរិក ដើម្បីជួយកសាងអនុវិទ្យាល័យថ្មីមួយ ឈ្មោះ "**អនុវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុន**" ស្ថិតនៅភូមិលីង្គ ឃុំអង្គរាជ ស្រុកព្រះស្តេច ខេត្តព្រៃវែងដូចមានរាយនាមខាងក្រោមនេះ :

១-លោក **ហ៊ីរ៉ូតូ ខាវ៉ៃ** អនុប្រធានទី១នៃសាលាត្រៀមចូលសាកលវិទ្យាល័យ**ខាវ៉ៃយូគី** និងជាអ្នកជាន់ ខ្ពស់នៃអង្គការមូលនិធិខ្មែរគាំទ្រការសិក្សា **ខាវ៉ៃយូគី** (Mr Hiroto Kawai , Kawaijuku vice president and top leader of C.E.S From Kawaijuku )

២-លោក **តាកេអូ នីវ៉ា** នាយកទូទៅ នៃសាលាត្រៀមចូលសាកលវិទ្យាល័យ ខាវ៉ៃយូគី និងជាមន្ត្រីសំខាន់នៃអង្គការមូលនិធិខ្មែរគាំទ្រការសិក្សា **ខាវ៉ៃយូគី** (Mr.Takeo Niwa, Director Of Kawaijuku andimportant staff of C.E.S from Kawaijuku )

៣-លោក **កាស៊ីយូគី ស៊ីស៊ីមី** ប្រធានសហព័ន្ធក្រុមហ៊ុននិងជាតំណាងអង្គការមូលនិធិខ្មែរ គាំទ្រការសិក្សា ពី **សាហ្គា** (Mr.Kazuyuki Tsutsumi, president of combine company and representative of cambodia Education Suport from Saga

៤-លោក **ស៊ីយ៉ូស៊ី មីគីណូ** ទីប្រឹក្សាកម្មវិធីអប់រំនៃសាលាត្រៀម **ខាវ៉ៃយូគី** និងជាមន្ត្រីជាន់ខ្ពស់របស់ អង្គការមូលនិធិខ្មែរ គាំទ្រការសិក្សាពី**ខាវ៉ៃយូគី**(Mr.Tsuyoshi Makino,Kawaijuku curriculum adviser and C.E.S.F Kawaijuku senior staff )

៥.-លោក **អាគីយ៉ាសឹ អ៊ីស៊ីកាវ៉ា** ជាមន្ត្រីជាន់ខ្ពស់សាលាត្រៀមចូលសកលវិទ្យាល័យ **ខាវ៉ៃយូគី** និង អង្គការមូលនិធិខ្មែរគាំទ្រការសិក្សាពី **ខាវ៉ៃយូគី**(Mr.Akiyasu Ishikawa, kawaijuku seniorstaff and C.E.S.F Kawajuku staff )

៦.-លោក **សាដាយ៉ូស៊ី គីន** ជាមន្ត្រីជាន់ខ្ពស់សាលាត្រៀមចូលសកលវិទ្យាល័យ **ខាវ៉ៃយូគី** និងជាមន្ត្រី ជាន់ខ្ពស់អង្គការមូលនិធិខ្មែរគាំទ្រការសិក្សាពី **ខាវ៉ៃយូគី** (Mr.Sadayoshi kin, kawaijuku senior and staff C.E.S.F Kawaifuku staff )

៧.-លោក **យូគីអូ អាគី** ជាប្រធានអង្គការមូលនិធិខ្មែរជំនួយការសិក្សាពីនិងជាគ្រូបង្រៀនភាសាអង់គ្លេសរបស់ **ខាវ៉ៃយូគី**(Mr.Yukio Aki,cambodia Education Assistance Fund(CEAF) leader and kawaijuku English teacher )

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

---

## អនុក្រឹត្យ លេខ ១៥៦ អនក្រ.-តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់ ខុទ្ទកាល័យរបស់សម្តេចនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា១.-** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនសិល្បៈករ និងសិល្បៈការិនី ដែលមានស្នាដៃឆ្នើមក្នុងវិស័យសិល្បៈវប្បធម៌ខ្មែរ ចំនួន ២៨ រូប ដូចមានរាយនាមខាងក្រោម :

១-លោកតា **យឹម សាំង** វិរសិល្បករ

| | | |
|---|---|---|
| ២-លោកតា | **ផ៊ី សារ៉ែ** | វិរសិល្បករ |
| ៣-លោកតា | **សួន ម៉ូ** ( ហៅ ឡូតូ ) | សិល្បករ |
| ៤ .-លោកតា | **ស៊ុម សុខ** ( ហៅអូកូឡូញ) | សិល្បករ |
| ៥-លោកតា | **រឡុំ សាំង** | វិរសិល្បករ |
| ៦-លោកយាយ | **សុទ្ធ សំអុន** | វិរសិល្បការិនី |
| ៧ .-លោកតា | **ម៉ៅ តៀង** | វិរសិល្បករ |
| ៨-លោកយាយ | **ឯម ឆាយ** | វិរសិល្បការិនី |
| ៩ .-លោកតា | **គង់ ពៅ** | វិរសិល្បករ |
| ១០-លោកយាយ | **រស់ យន** ( ហៅ ខុម) | វិរសិល្បការិនី |
| ១១ .-លោកតា | **អន សុខ** | វិរៈសិល្បៈករ |
| ១២-លោកយាយ | **រស់ គង់** | វិរសិល្បការិនី |
| ១៣ .-លោកតា | **ព្រីង សាយន** | វិរសិល្បករ |
| ១៤-លោកយាយ | **ឃី ម៉ុម** | វិរសិល្បការិនី |
| ១៥ លោក | **ផ្លុង ម៉ឿក** | សិល្បករ |
| ១៦-លោក | **ស្រៀង អ៊ី** | វិរសិល្បករ |
| ១៧ .-លោក | **អ៊ី សាមិត្ត** | សិល្បករ |
| ១៨ .-លោក | **ចេង គីយាន** | សិល្បករ |
| ១៩ .-លោក | **ពេជ្រ សុខា** | សិល្បករ |
| ២០ .-លោក | **យស់ សាត** | សិល្បករ |
| ២១ .-លោក | **ឈិន ឈាង** | សិល្បករ |
| ២២ .-ឯកឧត្តម | **ហ៊ុន ហេង** | សិល្បករ |
| ២៣-លោក | **ម៉ក់ ណេន** (ហៅសាឡាត់) | សិល្បករ |
| ២៤.-អ្នកស្រី | **ណយ សំណាង** | សិល្បការិនី |
| ២៥.-អ្នកស្រី | **ច័ន្ទ ធី** | សិល្បការិនី |
| ២៦ .-លោក | **ព្រហ្ម ម៉ាញ** | សិល្បករ |
| ២៧ .-លោក | **នេត្រ ម៉េ** | សិល្បករ |

២៨.-អ្នកស្រី **សួន សំអឿន** សិល្បការិនី

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យ នេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យ លេខ ១៥៧ អនក្រ.-តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ស្តីពី ការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនដល់សប្បុរសជន ទាំងក្នុងនិង ក្រៅ ប្រទេសចំនួន ១៣រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីជួយកសាងសាលារៀន

ព្រះវិហារ កុដិ សាលា ធម្មសភា របងវត្ត ក្នុងស្រុកអង្គរបូរី ខេត្តតាកែវ ដូចមានរាយនាមខាងក្រោមនេះ :

**ក.មេដាយមាសស្ថាបនាជាតិ :**

១-ឯកឧត្តម **ច័ន្ទ តុងអ៊ីវ** រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ទឹកប្រាក់ចំនួន ៦៥.០០០.០០០រៀល

២-លោក **យូ ផាសិទ្ធិ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២៥.០០០ USD និង ៣.០០០.០០០ រៀល

៣-លោកយាយ **កែវ ហ៊ាម** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.៥០០ USD

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **ឈុប អ៊ុំ** និងអ្នកស្រី **សេង គង់** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២០.០០០.០០០ រៀល

២-លោក **ឌី ឌី** និងលោកយាយ **អេង ចាន់យ៉ា** ថវិកាចំនួន ៥.០០០ USD

**គ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-លោក **អ៊ិត សារុន** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ ថវិកា ចំនួន ៩.៥០០.០០០ រៀល

២-លោក **ហង់ ទ្រី** អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ ថវិកា ចំនួន ៧.៥០០.០០០ រៀល

៣-ព្រះតេជគុណ **ឆេត នាង** ព្រះសង្ឃវត្តកោះ ថវិកា ចំនួន៤.៣០០ USD

៤-លោក **ឈាង ហ៊ី** អភិបាលស្រុកអង្គរបូរី ថវិកា ចំនួន៤.៧៥០ USD

៥-លោកតា **មៀវ ស្រ៊ុយ** ប្រធានគណៈកម្មការសាងសង់វត្តកោះ ឃុំបាស្រែ ថវិកា ចំនួន២.៤៥០ USD

៦-លោក **ស៊ឹម ហ៊ួ** អនុប្រធានគណៈកម្មការសាងសង់វត្តកោះ ឃុំបាស្រែ ថវិកា ចំនួន២.៩៧៥ USD

៧-លោក **សេង ថន** នាយកសាលាបឋមសិក្សាវត្តកោះ ឃុំបាស្រែ ថវិកា ចំនួន ១.៤៥២ USD

៨-លោក **ពៅ នួន** មេភូមិ តាអី ឃុំបាស្រែ ថវិកា ចំនួន១.៨៤១ USD

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យ នេះឱ្យ ទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យ លេខ ១៥៨ អនក្រ.-តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

---

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែល ប្រកាសប្រើ ឱ្យច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

.-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកោះកុង

**សំរេច**

**មាត្រា១.-**ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ ០៤អង្គនិងជូន សប្បុរសជន ០២រូប ដែលបានបរិច្ចាគថវិកាចូលរួមក្នុងការសាងសង់សំណង់នានា លើវិស័យ ព្រះពុទ្ធសាសនា នៅក្នុងស្រុកកំពង់សិលា ខេត្តកោះកុង ដូចមានរាយព្រះនាមនិងនាមខាង ក្រោមនេះ :

**ក-មេដាយមាសស្ថាបនាជាតិ :**

ព្រះតេជគុណ **ភាន់ សុផល** អតីតចៅអធិការវត្តកំពង់សលា ថវិកា ១១.០២៥ USD

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១.-ព្រះតេជគុណ **ជាត ទិច** ចៅអធិការវត្តកំពង់សិលា ថវិកា ៥.៣៣៤ USD

២.-ព្រះតេជគុណ **ទូច នួន** ចៅអធិការវត្តសាមគ្គីគីរីស្ទឹងឆាយ ថវិកា៥.១៥២ USD

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១.-ព្រះតេជគុណ **ឆន ទណ្ណាវ៉ា** ចៅអធិការវត្តក្អោង ថវិកា ៤.១៨៦ USD

២.-លោក **ជីក ហួ** អភិបាលស្រុកកំពង់សីលា ថវិកា ៣.១៣៣ US

៣-លោក **ឈឹម ឆេខ** មេឃុំកំពង់សីលា ថវិកា ២.៥៣៣ US

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យ នេះឱ្យមមូលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

បាត្តលេខានិងត្រា

**ហ៊ុន សែន**

---

## អនុក្រឹត្យ លេខ ១៥៩ អនក្រ.បក
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៩/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៩ស្តីពីការប្រកាស ប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

**សំរេច**

**មាត្រា១.-** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូន សប្បុរសជនចំនួន ១៣រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនជួយកសាងអនុវិទ្យាល័យ សុខ អាន លាយបូរ រួមមាន អាគារសិក្សា ០៣ខ្នង ១៥បន្ទប់ ក្លោងទ្វារ ផ្លូវថ្នល់ និងចាក់ដីកែលំអទីធ្លាសាលារៀន នៅឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោមនេះ :

**ក.-មេដាយមាសស្ថាបនាជាតិ :**

១.-ព្រះតេជគុណ **ខ្មៅ ផេង** ព្រះគ្រូចៅអធិការវត្តលាយបូរ ប្រាក់ចំនួន ១១.២៥០ ដុល្លារអាមេរិក

២.-ព្រះតេជគុណ **អ៊ុក សុផល** ព្រះគ្រូសូត្រស្តាំវត្តលាយបូរ ប្រាក់ចំនួន ១២.៤២១ ដុល្លារអាមេរិក

៣- ឯកឧត្តម **មិន ឃិន** អគ្គលេខាធិការនិងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មការរៀបចំបុណ្យ ជាតិ-អន្តរជាតិ ប្រាក់ចំនួន ១០.១០៥ ដុល្លារអាមេរិក

៤.-លោក **សៀង ឈុនឡី** អនុប្រធានទីចាត់ការគតនិងរដ្ឋាករ ប្រាក់ចំនួន ១០.១០៥ ដុល្លារអាមេរិក

**ខ.-មេដាយប្រាក់ស្ថាបនាជាតិ :**

១.-លោក **ហុង ថា** ប្រធាននាយកដ្ឋានពន្ធដារ ប្រាក់ចំនួន ៨.៣០០ដុល្លារអាមេរិ

២-លោក **គិត សែនសុរិយា** ប្រធានក្រុមហ៊ុនសែនសូរិចស៊ីម ប្រាក់ចំនួន ៨.១០០ ដុល្លារអាមេរិក

**គ.-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-លោក **អោម ហាន** អភិបាលស្រុកត្រាំកក់ ប្រាក់ចំនួន ៤.០៥០ ដុល្លារអាមេរិក

២.-លោកវរៈសេនីយ៍ឯក **ឡេង ហ៊ា** អនុប្រធាននាយកដ្ឋានព្រហ្មទ័ណ្ឌ ប្រាក់ចំនួន ២.៣០០ដុល្លារអាមេរិក

៣.-លោកវរសេនីយ៍ឯក **គង់ សំអឿន** មេបញ្ជាការតំបន់សឹករងខេត្តតាកែវប្រាក់ចំនួន ២.១៥០ ដុល្លារអាមេរិក

៤.-លោក **អ៊ុយ ចាន់បូរ** ប្រាក់ចំនួន ២០០០ ដុល្លារអាមេរិក

៥.-លោកវរសេនីយ៍ទោ **សៅ សៀប** មន្ត្រីភស្តុភារក្រសួងការពារជាតិប្រាក់ចំនួន ១.៨០០ ដុល្លារអាមេរិក

៦.-លោក វរសេនីយ៍ទោ **ស៊ិន ថន** ស្នងការរងនគរបាលខេត្តតាកែវ ប្រាក់ចំនួន ១.៥០០ ដុល្លារអាមេរិក

៧.-លោក **មាន់ ទ្រី** អនុប្រធានមន្ទីរកសិកម្មខេត្តតាកែវ ប្រាក់ចំនួន ១.៥០០ដុល្លារអាមេរិក

**មាត្រា២..** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យ លេខ ១៦០ អនក្រ.បក

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

.-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

.-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្ដីពីការប្រកាស ប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

.-តាមសំណើរបស់ អភិបាលខេត្តកំពង់ចាម

**សំរេច**

**មាត្រា១.-** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ០៦រូប ដែលបាន បរិច្ចាគធនធានជាថវិកាផ្ទាល់ខ្លួន ក្នុងការកសាងសមិទ្ធផលនានាក្នុងស្រុកបាធាយ និងស្រុក កំពង់សៀម ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ :

**ក.-មេដាយមាសស្ថាបនាជាតិ :**

១-លោកជំទាវ **ហោណាំ ប៊ុរី** ប្រាក់ចំនួន ១៨.៥០០ដុល្លារអាមេរិក

២.-ឯកឧត្ដម **ហោ សុធន់** ប្រាក់ចំនួន ១៣.០០០ ដុល្លារអាមេរិក

៣-លោក **ចាយ សរ៉ាងអ៊ី** ប្រាក់ចំនួន ១១.៧៥០ ដុល្លារអាមេរិក

៤-លោកស្រី **លុយ គន្ធី** ប្រាក់ចំនួន ១១.៧៥០ ដុល្លារអាមេរិក

៥-លោក **សាន តារីនី** ប្រាក់ចំនួន ១១.០០០ ដុល្លារអាមេរិក

**ខ.-មេដាយសំរិទ្ធស្ថាបនាជាតិ :**

.-លោក **យិន គឹមហ៊ន** ប្រាក់ចំនួន ៣.២៣៧ដុល្លារអាមេរិក

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ១៦១ អនក្រ.បក
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ដែល ប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

.-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើររបស់ អភិបាលខេត្តកំពង់ចាម

## សម្រេច

**មាត្រា១.**-ត្រូវបានបំពាក់ **មេដាយសិរីវឌ្ឍនស្ថាបនាជាតិ** ជូនសប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិកចំនួន ០៥ រូប បានបរិច្ចាគថវិកាផ្ទាល់ខ្លួនក្នុងការទិញស្រូវចែកជូនប្រជាពលរដ្ឋ នៅឃុំសំពងជ័យ និងឃុំត្រពាំងគ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ :

១-លោក **ឌុល ហ៊ន** អ្នកស្រី **ឈា ហឿន** ថវិកាចំនួន ១.៤៤០ ដុល្លារអាមេរិក

២-លោក **ឃុន ចំរើន** អ្នកស្រី **ខេង ហ៊ន** ថវិកាចំនួន ១.៣៤០ ដុល្លារអាមេរិក

៣-លោក **ឌី អៀត** អ្នកស្រី **តាន់ សុខា** ថវិកាចំនួន ១.៣៤០ ដុល្លារអាមេរិក

៤-ឧបាសក **ម៉ែន ទិត** ឧបាសិកា **ស្វាន់ ឈឿន** ថវិកាចំនួន ១.៣៤០ ដុល្លារអាមេរិក

៥.-ឧបាសក **ផន ទីវន** ថវិកាចំនួន ១.៣៤០ ដុល្លារអាមេរិក

**មាត្រា២.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យ នេះឱ្យទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ១៦២ អនក្រ.-តត
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៩/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៩ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

## សម្រេច

**មាត្រា១.-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម **អ៊ឹច ថុង** ទីប្រឹក្សាសម្តេចប្រធាន ព្រឹទ្ធ សភា និងជានាយយកវិទ្យាស្ថានជាតិគ្រប់គ្រង ដែលបានរំលែកថវិកា ជាមូលនិធិរបស់ វិទ្យាស្ថាន ជាតិគ្រប់គ្រង ភ្នំពេញ ជួយស្តារនិងជួសជុលអាគារ( អតីតសាលាសកល) និងបំពាក់ សំភារៈបរិក្ខារ គ្រឿងសង្ហារិម គ្រប់ថ្នាក់សិក្សា និងសាលប្រជុំ សរុបទឹកប្រាក់ចំនួន ៥០០.០០០ដុល្លារអាមេរិក ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យ នេះឱ្យ ទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ១៦៣ អនក្រ.បក
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

.-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការប្រកាសប្រើក្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ក្រសួងអប់រំយុវជននិងកីឡា

### សម្រេច

**មាត្រា១.**-ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនដល់ប្រជាជនស្រុក ASHIKITA នៅខេត្ត KUMAMOTO ប្រទេសជប៉ុន ដែលបានជួយសាងសង់អាគារសិក្សា ០១ខ្នង មាន ០៥ បន្ទប់ នៅសាលាបឋមសិក្សា បត់សិរមាន់ ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ចំណាយអស់ទឹកប្រាក់ចំនួន ២៣.០០០ដុល្លារអាមេរិក ។

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងអប់រំ យុវជននិងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

≈≈≈

## ២. សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ២០ ស.ស.រ**

**ស្តីពីការបង្កើត**

**គណកម្មការអន្តរក្រសួង ដើម្បីដោះស្រាយដី**

**ដែលមានទីតាំង នៅខាងក្រោយជាប់ អូតែលសុខា ក្រុងព្រះសីហនុ**

---

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការ បង្កើតគណកម្មការ ដោះស្រាយបាតុភាពដីធ្លី នៅតាមបណ្តាខេត្ត-ក្រុងទូទាំងប្រទេស

-បានឃើញសេចក្តីសំរេចលេខ ១១ សសរ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០០០ ស្តីពីការបង្កើតគណកម្មការ ដោះស្រាយដីធ្លី និងគ្រួសារប្រជាជនស្នាក់នៅបរិវេណអតីត ម៉ូតែលសុខា ក្រុងព្រះសីហនុ

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** បង្កើតគណកម្មការអន្តរក្រសួងដើម្បីដោះស្រាយដីដែលមានទំហំចំនួន ៧ ហិកតា ៤២ អា និង ៨៧ សង់ទីអា ស្ថិតនៅខាងក្រោយជាប់ អូតែលសុខា ក្រុងព្រះសីហនុ សំរាប់រៀបចំជាឧទ្យានសាធារណៈ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១.-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ | ប្រធាន |
| ២.-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច | អនុប្រធាន |
| ៣.-ឯកឧត្តមរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |

៤.-ឯកឧត្តមរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៥.-ឯកឧត្តមរដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

៦.-ឯកឧត្តមអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក

៧.-ឯកឧត្តមមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៨.-ឯកឧត្តមអភិបាលក្រុងព្រះសីហនុ សមាជិក

**ប្រការ២** : គណកម្មការអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ :

-ចុះស្រាវជ្រាវ និងត្រួតពិនិត្យបាតុភាពរំលោភបំពានលើដីខាងលើ ដែលបង្កឡើងដោយរូបវន្តបុគ្គលក្តីឬដោយ នីតិបុគ្គលក្តី ។

-លើកវិធានការដើម្បីដោះស្រាយតាមផ្លូវច្បាប់ នូវរាល់បាតុភាពរំលោភបំពានខាងលើឱ្យមានប្រសិទ្ធភាព ព្រមទាំងស្រាវជ្រាវរកឱ្យឃើញបុគ្គលឬអង្គភាពដែលបានប្រព្រឹត្តខុសឆ្គងក្នុងការរំលោភយកដីរដ្ឋ ឬហ៊ានចេញប័ណ្ណកម្មសិទ្ធិទៅឱ្យបុគ្គលណាមួយ ដើម្បី កាន់កាប់លើដី នោះ ។

-លើកយោបល់ដើម្បីសុំការសំរេចពីរាជរដ្ឋាភិបាល ក្នុងករណីដែលមានការចាំបាច់ ព្រមទាំងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលការងារដែលអនុវត្តបាន ។

**ប្រការ ៣** : គណកម្មការអន្តរក្រសួងនេះ មានសិទ្ធិរៀបចំលេខាធិការដ្ឋានមួយ ជាជំនួយការងារទៅតាមសភាពការណ៍ជាក់ស្តែង និងមានសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងរៀបចំ ដែនដីនគរូបនីយកម្ម និងសំណង់ដើម្បី សំរួលការងារ ។

**ប្រការ ៤** : សមាជិកគណៈកម្មការអន្តរក្រសួងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈ -កម្មការ

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច សហរដ្ឋន្ត្រីក្រសួងមហាផ្ទៃ សហក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អភិបាលក្រុងព្រះសីហនុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង -ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយ

មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

## III. ការងារបណ្ដាក្រសួង

### ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិង ថាមពល

### ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០១

**ប្រកាសលេខ ២៧៧ ឧរថក.ប្រក**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តមសីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជា ធិបតី ស្ដីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្មរ៉ែនិងថាមពល

-បានឃើញលិខិតលេខ ៨៨០ /០១.គ.វក ចុះថ្ងៃទី ២០.-៣.-២០០១ របស់ក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា

-បានឃើញលិខិតលេខ ០៣៩ បស្ក កសន ចុះថ្ងៃទី ២៦.-៣.-២០០១ របស់មន្ទីរ បរិស្ថាន ក្រុងព្រះសីហនុ

-បានឃើញលិខិតលេខ ១៧៨ អភ. កសន ចុះថ្ងៃទី ១៧.-០៣.-២០០១ របស់សាលាក្រុង ព្រះសីហនុ

-យោងពាក្យស្នើរបស់លោក តាំង ថេងសៀវ ចុះថ្ងៃទី ២៨.-០៣.-២០០១

**សំរេច**

**ប្រការ១ :** អនុញ្ញាតឱ្យលោក តាំង ថេងសៀវ សញ្ជាតិកម្ពុជា ភេទប្រុសអាយុ ៥០ឆ្នាំ កាន់អត្តសញ្ញាណបណ្ណ លេខ ០១៣០៥៣ ភ.៣ ចុះថ្ងៃទី ២០ ខែតុលាឆ្នាំ ២០០១

បង្កើតសហគ្រាសផលិតកាបូប វ៉ាលីសដែលមានឈ្មោះថា "យូណាយខេម អ៊ិនវេសខប" (UNICAM INVEST CORP) ដែលមានទីតាំងស្ថិតនៅមណ្ឌល ១ សង្កាត់លេខ២ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

**ប្រការ ២** : សហគ្រាសត្រូវរៀបចំគ្រឿងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាម ពល ។

**ប្រការ ៣** : សហគ្រាសត្រូវបានអនុញ្ញាតឱ្យ ផលិតកាបូប វ៉ាលីស ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់ខ្លួន ជូន ក្រសួងឧស្សាហកម្មរ៉ែនិងថាម ពល ។

**ប្រការ ៤** : សហគ្រាសត្រូវលើកបង្ហាញ ផ្លាកឈ្មោះ របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេង ទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខសហគ្រាស ។

**ប្រការ ៥** : ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំង ឬបង្កើតសាខា សហគ្រាសត្រូវសុំអនុញ្ញាតពីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ។

**ប្រការ ៦** : ការនាំចេញផលិតផលសំរេច សហគ្រាសត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ដល់តកប្ល ពី ក្រសួងឧស្សាហកម្មរ៉ែនិងថាម ពល ។

**ប្រការ ៧** : សហគ្រាសត្រូវធានាសុវត្ថិ ភាពឧស្សាហកម្ម និងគុណភាពផលិតផល ព្រមទាំងត្រូវគោរព ឱ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់ បទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនិងផលិតកម្ម អាជីវកម្មរបស់សហគ្រាស ។

**ប្រការ ៨** : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនិងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនិងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៩** : អគ្គនាយកឧស្សាហកម្ម នៃ ក្រសួងឧស្សាហកម្មរ៉ែនិងថាម ពល ប្រធានមន្ទីរ ឧស្សាហកម្ម រ៉ែ និងថាមពលក្រុងព្រះសីហនុ និងប្រធានសហគ្រាស " យូណាយខេម អ៊ិនវេសខប " ត្រូវអនុវត្តប្រកាស នេះតាមមុខការរៀង១ខ្លួន ។

**ប្រការ ១០** : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខានិងត្រា

**ស៊ុយ សែម**

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០១

**ប្រកាសលេខ ២៧៨ ឧរ ថកឧ.ប្រក**

~~~

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តមសីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មរ៉ែនិងថាមពល

-បានឃើញអនុក្រឹត្យ លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល

បានឃើញលិខិតលេខ ១១៨/០១.គ.វក ចុះថ្ងៃទី ១១.-០១.-២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-បានឃើញលិខិតលេខ ៣០៤ បស្ត សណ.វហ.បស្ត ចុះថ្ងៃទី ១៦.-៣.-២០០១ របស់ក្រសួងបរិស្ថាន

-បានឃើញលិខិតលេខ ១៦៩១លអ.ស ចុះថ្ងៃទី ២៤.-៦.-១៩៩៩ របស់សាលាក្រុងភ្នំពេញ

-យោងពាក្យស្នើរបស់លោក ក្រុមហ៊ុន ( ខេមបូឌា ) ហ្សុងហ្សិនអ៊ិនជីនារីង អេនមីស៊ីណើរី ខូអិលធីឌី ចុះថ្ងៃទី ៣០-០៣-២០០១

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឱ្យក្រុមហ៊ុន ( ខេមបូឌា ) ហ្សុងហ្សិន អ៊ិនជីនារីង អេនមីស៊ីណើរី ខូអិលធីឌី CAMBODIA ZONG SHEN ENGINEERING& MACHINERY Co,LTD តំណាងដោយលោក CHENG CHUNG KONG សញ្ជាតិចិនហុងកុង ភេទប្រុសអាយុ ៤៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ H 90088614 ចុះថ្ងៃទី ១៥-៧-២០០០ បង្កើតរោងចក្រ ផ្គុំតម្លើងម៉ូតូដែល មានផ្លាកឈ្មោះថា ( ខេមបូឌា ) ហ្សុងហ្សិន អ៊ិនជីនារីង អេនមីស៊ីណើរី មានទីតាំងស្ថិតនៅភូមិព្រៃទា សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
~~~

**ប្រការ ៣** : រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ " ផ្គុតម្លើងម៉ូតូ " ទៅតាមគំរូដែលបានតំកល់ទុក ហើយត្រូវធ្វើរបាយ ...ណើប្រចាំអំពីស្ថានភាពផលិតកម្មរបស់ខ្លួន ជូនក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ។

**ប្រការ ៤** : ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមា នទំហំធំជាង និងនៅពីលើ អក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ ៥** : ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬបង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំអនុញ្ញាតពី ក្រសួងឧស្សាហកម្មរ៉ែនិងថាម ពល ។

**ប្រការ ៦** : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្មរ៉ែនិងថាម ពល ។

**ប្រការ ៧** : ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និងគុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់ បទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

**ប្រការ ៨** : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនិងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៩** : អគ្គនាយកឧស្សាហកម្មនៃក្រសួងឧស្សាហកម្មរ៉ែនិងថាម ពល ប្រធានមន្ទីរ ឧស្សាហកម្មរ៉ែនិងថាមពលរាជធានីភ្នំពេញ និងប្រធាន ក្រុមហ៊ុន ( ខេមបូឌា ) ហ្សុងហ្សិន អ៊ិនជីនារីង អេនមីស៊ុ - ណើរី ខូអិលធីឌី ត្រូវអនុវត្ត ប្រកាស នេះតាមមុខការរៀង១ខ្លួន ។

**ប្រការ ១០** : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខានិងត្រា

**ស៊ុយ សែម**

## ២- ទីស្តីការរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០១

**ប្រកាសលេខ ០០៧/០១ ទ.រ.ព.អ.ប្រក**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/០៦ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តី ពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា.-ព្រឹទ្ធសភា និង អធិការកិច្ច

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និង អធិការកិច្ច

-យោងតាមសំណើរបស់អគ្គនាយកដ្ឋានអធិការកិច្ច និងមតិរបស់អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ

**សំរេច**

**ប្រការ ១ :** ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន០៤រូបនៅក្នុងអគ្គនាយកដ្ឋានអធិការកិច្ច ដូចមានរាយនាមដូចខាងក្រោមនេះ :

១-លោក **ទី ជីម** ជាអនុប្រធាននាយកដ្ឋានអធិការកិច្ច

២-លោក **ឆាក់ ម៉េងអ៊ុយ** ជាអនុប្រធាននាយកដ្ឋានតាមដានការអនុវត្តន៍ច្បាប់

៣-លោក **សោម សាធាន**ជាអនុប្រធាននាយ កដ្ឋានទទួលពាក្យបណ្តឹងនិង អង្កេតស្រាវជ្រាវ

៤-លោក **អ៊ូច សារី** ជាអនុប្រធាននាយកដ្ឋានវិវាទកម្ម

**ប្រការ ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការ ទូទៅ.អគ្គនាយកនៃអគ្គនាយក ដ្ឋានអធិការកិច្ច អគ្គនាយកនៃអគ្គនាយកដ្ឋានទំនាក់ទំនងជា មួយរដ្ឋសភា.-ព្រឹទ្ធសភា នាយកខុទ្ទកាល័យ និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធ ភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ឃុន ហាំង**

—

## ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សេចក្តីសំរេច

ភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ៩១ ក.ធ.ស សរ**

**រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ធស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធម្មការនិងសាសនា

យោងពាក្យស្នើសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តនៃ **ក្រុមប្រឹក្សាប្រិយសម្ព័ន្ធគ្រីស្តបរិស័ទកម្ពុជា** នៅខេត្តសៀមរាប របស់លោក **ឡុន ឆាយ** អាយុ ៣០ឆ្នាំ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ១៩៩៩

-យោងចំណារបញ្ជូន របស់សាលាខេត្តសៀមរាបលេខ ១៨២ ខសរ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០១

**សំរេច**

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ **ក្រុមជំនុំព្រះជាម្ចាស់ខេត្តសៀមរាប** មួយកន្លែងដែលមានទីតាំងស្ថិតនៅ ភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ **ក្រុមជំនុំព្រះជាម្ចាស់ខេត្តសៀមរាប** ត្រូវអនុញ្ញាត ឱ្យប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់សាសនាគ្រីស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣ :** បរិស័ទនៃ សាខាស្នាក់ការព្រះគ្រីស្តឈ្មោះ **ក្រុមជំនុំព្រះជាម្ចាស់ខេត្តសៀមរាប** ត្រូវគោរពនិងអនុវត្ត ឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទប្បញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះ ពាល់ដល់សិទ្ធិ សេរីភាពខាង ជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤ :** រាល់ការអនុវត្តន៍ទាំងលឡាយណា ដែលផ្ទុយនឹងសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ ជាធរមាន ។

**ប្រការ ៥ :** ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល.-អគ្គនាយកដ្ឋានធម្មការ **នាយកដ្ឋានពាហិរសាសនា** គ្រប់ស្ថាប័ន-អង្គភាពដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ :** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ជា សាវឿន**

ភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ៩២ ក.ធ.ស សរ

## រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈឆ្នាំ១៩៩៨ស្តីការ រៀបចំនិងារប្រព្រឹត្តិទៅរបស់ក្រសួងធម្មការនិងសាសនា

-យោងពាក្យស្នើសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តនៃ**គ្រុមប្រឹក្សាប្រយ័សម្ព័ន្ធគ្រីស្ត បរិស័ទកម្ពុជា** រាជធានីភ្នំពេញ របស់លោក **សៅ ទិវៈ** អាយុ ២១ឆ្នាំ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០១

-យោងចំណារឯកភាពរបស់សាលាក្រុងភ្នំពេញ លេខ ៤៤៤ លស ស ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ **ព័ន្ធកិច្ចពេនទីកូសបរិសុទ្ធបេសកកម្ម ពិភពលោក** មួយកន្លែងដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ ៤៥c ក្រុមទី១០ សង្កាត់ទួលទំពូងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**ប្រការ ២ :** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ត **ព័ន្ធកិច្ចពេនទីកូសបរិសុទ្ធបេសកកម្មពិភពលោក** ត្រូវអនុញ្ញាតឱ្យប្រើប្រាស់និងផ្សព្វផ្សាយ នូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រីស្តដែលមានលក្ខណៈ ជាសាសនាសុទ្ធសាធ ។

**ប្រការ ៣ :** បរិស័ទនៃសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ **ព័ន្ធកិច្ចពេនទីកូសបរិសុទ្ធបេសកកម្មពិភពលោក** ត្រូវគោរពនិងអនុវត្ត ឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទប្បញ្ញត្តិ ផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធសន្យាដាច់ ខាតមិន ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពខាង ជំនឿសាសនា និងសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

**ប្រការ ៤ :** រាល់ការអនុវត្តន៍ទាំងលឡាយណា ដែលផ្ទុយនឹងសេចក្តីសំរេចខាងលើនេះ ត្រូវទទួល ទោសជាធរមាន ។

**ប្រការ ៥ :** ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល.-អគ្គនាយកដ្ឋានធម្មការ **នាយកដ្ឋានពាហិរសាសនា** គ្រប់ស្ថាប័នអង្គភាពដែលមានភារកិច្ច ពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦ :** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ជា សាវឿន**

# សេចក្តីសំរេច

ភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ៩៣ ក.ធ.ស សរ**

~~~

**រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្តីការរៀបចំនិងការ ប្រព្រឹត្តិទៅរបស់ក្រសួងធម្មការនិងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះនៃព្រះពុទ្ធសាសនាមហាយានមីឡី (ចិន) នៅរាជធានី ភ្នំពេញ របស់លោក **តុង ហ៊ុចផាត** អាយុ ៦៤ឆ្នាំ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០០

-យោងចំណារឯកភាពរបស់សាលាក្រុងភ្នំពេញ លេខ ៣៩៤ លស ស ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះ នៃព្រះពុទ្ធសាសនាមហាយានមីឡី **(ចិន)** មានឈ្មោះ **ឆៀនឈើមីឡី** មួយកន្លែងដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ ៧៧ AEo ផ្លូវលេខ៣ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**ប្រការ ២ :** សាខាស្នាក់ការថ្វាយបង្គំ **ឆៀនឈើមីឡី** ត្រូវអនុញ្ញាតឱ្យប្រើប្រាស់និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់ព្រះពុទ្ធសាសនាមហាយានមីឡី ដែលមានលក្ខណៈ ជាសាសនាសុទ្ធសាធ ។
~~~

**ប្រការ ៣ :** បរិស័ទនៃសាខាស្នាក់ការ **ឆឿនឈឿមីឡី** ត្រូវគោរពនិងអនុវត្ត ឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទប្បញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាព ខាង ជំនឿសាសនា និងសណ្តាប់ ធ្នាបរបៀបរៀបរយសង្គម ។

**ប្រការ ៤ :** រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមានជា ធរមាន ។

**ប្រការ ៥ :** ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល.-អគ្គនាយកដ្ឋានធម្មការ **នាយកដ្ឋានពាហិរសាសនា** គ្រប់ស្ថាប័នអង្គភាពដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦ :** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ជា សាវឿន**

ភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ៩៤ ក.ធ.ស សរ

~~~

## រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តិទៅរបស់ក្រសួងធម្មការនិងសាសនា
~~~

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ទនិកាយ**ភាតូលិក**នៅខេត្តកំពង់ចាម របស់លោកស្រី **ពៅ សាន់** អាយុ ៥០ឆ្នាំ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០០

-យោងចំណារបញ្ជូនរបស់សាលាខេត្តកំពង់ចាម លេខ ៣០៣ កច ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំសាសនាគ្រីស្ទ ឈ្មោះ **ភាតូលិកភូមិថ្មពេជ្រទី២** មួយកន្លែងដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ ៣៦ ក្រុមទី១១ ភូមិថ្មពេជ្រទី២ ឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្តឈ្មោះ **ភាតូលិកភូមិថ្មពេជ្រទី២** ត្រូវអនុញ្ញាតឱ្យ ប្រើប្រាស់និងផ្សព្វផ្សាយ នូវរាល់ឯកសារផ្សេងៗ របស់សាសនាគ្រីស្ទ ដែលមានលក្ខណៈ ជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិវេណនៃសាខាស្នាក់ការ **ភាតូលិកភូមិថ្មពេជ្រទី២** ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវ មឹុងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទប្បញ្ញត្តិ ផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងឱ្យបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពខាងជំនឿសាសនា និងសណ្តាប់ ធ្នាបរបៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជា ធរមាន ។

**ប្រការ ៥** : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ **នាយកដ្ឋានពាហិរសាសនា** គ្រប់ស្ថាប័ន-អង្គភាពដែលមានភារកិច្ច ពាក់ព័ន្ធត្រូវសហការ អនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦** : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ខា សារឿន**

៖៖៖

ភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ៩៥ ក.ធ.ស សរ**

**រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈឆ្នាំ១៩៩ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តិទៅរបស់ក្រសួងធម្មការនិងសាសនា

.-យោងពាក្យស្នើសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះនៃព្រះពុទ្ធសានាមហាយានមីឡី **(ចិន)** នៅខេត្តកំពង់ ចាម របស់លោក ស្រី **ឡេង សុខណា** អាយុ ២៨ឆ្នាំ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០០

-យោងចំណារបញ្ជូនរបស់សាលាខេត្តកំពង់ចាម លេខ ៣០៦៩ កច ចុះថ្ងៃទី ២១ខែ វិច្ឆការ ឆ្នាំ ២០០០

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំនៃព្រះពុទ្ធសាសនាមហាយានមីឡី **(ចិន)** មាន ឈ្មោះ"**ធានយាន** " មួយកន្លែងដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ ២៤ផ្លូវលេខ ៧ ក្រុមទី១ ភូមិមេមត់កណ្តាល ស្រុកមេមត់

**ប្រការ ២ :** សាខាស្នាក់ការថ្វាយបង្គំ "**ធានយាន** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់និងផ្សព្វផ្សាយ នូវរាល់ឯកសារ ផ្សេងៗ របស់ព្រះសាសនាមហាយានមីឡី ដែលមានលក្ខណៈ ជាសាសនាសុទ្ធសាធ ។

**ប្រការ ៣ :** បរិស័ទនៃសាខាស្នាក់ការ "**ធានយាន** " ត្រូវគោរពនិងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទប្បញ្ញត្តិផ្សេងៗរបស់ក្រសួង ធម្មការ និងសាសនា។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវចេះនិយាយ-ចេះសរសេរជាភាសា ខ្មែរហើយ ត្រូវមាន

សាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធ សន្សាដាច់ខាតមិន ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពខាង ជំនឿសាសនា និងសណ្តាប់ ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤ :** រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយនិងសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសជាធរមាន ។

**ប្រការ ៥ :** ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល.-អគ្គនាយកដ្ឋានធម្មការ **នាយកដ្ឋានពាហិរសាសនា** គ្រប់ស្ថាប័នអង្គភាពដែលមានភារកិច្ចការពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦ :** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ជា សាវឿន**